



# ដំណឹងសូត្រព្រះត្រៃបិដកអន្តរជាតិ

# លើកទី១១ នៅទីក្រុងពុទ្ធគយា ប្រទេសឥណ្ឌា

យើងខ្ញុំជាក្រុមស្ម័គ្រចិត្តបកប្រែអត្ថបទពីភាសាអង់គ្លេស មកជាភាសាខ្មែរអំពីការផ្សព្វផ្សាយ

រកអ្នកស្ម័គ្រចិត្តដើម្បីបំរើកិច្ចការងារក្នុងកម្មវិធីសូត្រព្រះត្រៃបិដកអន្តរជាតិលើកទី១១

នៅទីក្រុងពុទ្ធគយា ប្រទេសឥណ្ឌា ដែលរៀបចំដោយអង្គការអន្តរជាតិនៃពន្លឺព្រះពុទ្ធព្រះធម៌

( Light of Buddhadharma Foundation International ) ដែលមានលោកស្រី

**វ៉ាងម៉ូ ឌិចស៊ី** Wangmo Dixey ជាប្រធាន យើងមានសេចក្តីសោមនស្សដោយបាន

ទទួលការស្នើរសុំអំពីលោកស្រីអោយដាក់ផ្សាយអត្ថបទនេះតាមរយៈប្រព័ន្ធ Facebook

ប្រគេន និងជូនព័ត៌មានដល់ពុទ្ធបរិស័ទទាំងឡាយដោយមានការអនុញ្ញាតិយល់ព្រមពី

ព្រះគ្រូទេវសត្ថា **ញើយ មេត្តា** ព្រះចៅអធិការវត្តខ្មែរពុទ្ធគយា នៅប្រទេសឥណ្ឌា

និងជាព្រះចៅអធិការវត្តកោះមេត្តាពោធិវង្ស រាជធានីភ្នំពេញ នៃប្រទេសកម្ពុជា។

នេះជាឆ្នាំទីពីរដែលប្រទេសកម្ពុជាយើង មានកិត្តិយសទទួលតំណែងជាម្ចាស់ផ្ទះក្នុងការ

ទទួលបដិសណ្ឋារកិច្ច ភ្ញៀវជាតិ និង អន្តរជាតិ ក្រោមការដឹកនាំដោយព្រះគ្រូទេវសត្ថា

**ញើយ មេត្តា** ក្នុងកម្មវិធីសូត្រព្រះត្រៃបិដកអន្តរជាតិលើកទី១១ នៅទីក្រុងពុទ្ធគយា

ប្រទេសឥណ្ឌា ជាទីកន្លែងដែលព្រះពុទ្ធគ្រប់ព្រះអង្គតែងបានត្រាស់ដឹងឡើងក្នុងលោក។

កម្មវិធីនេះ ចាប់ផ្តើមពីថ្ងៃទី ២ ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៥។

អាស្រ័យហេតុនេះ សូមនិមន្ត និងអញ្ជើញអានព័ត៌មានបន្ថែមដែលទាក់ទងនឹងកម្មវិធី

បុណ្យសូត្រព្រះត្រៃបិដកអន្តរជាតិដែលបានអធិប្បាយក្នុងអត្ថបទភ្ជាប់មកជាមួយ ហើយសូមមេត្តាចុះឈ្មោះអោយបានរួសរាន់តាមរយៈគេហទំព័រដូចខាងក្រោមនេះ

WWW.TIPITAKACHANTINGCOUNCIL.ORG

សូមអរគុណទុកជាមុន និងសង្ឃឹមថាពុទ្ធបរិស័ទជាច្រើន នឹងចូលរួមក្នុងពិធីបុណ្យនេះ

អោយបានអធឹកអធ័ម ដើម្បីជាកិត្តិយសជាតិ សាសនា របស់យើងទាំងអស់គ្នា។

សូមប្រគេន និងជូនពុទ្ធពរទាំងឡាយ បួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរព្រះគុណ និង អរគុណ**

## ក្រុមសមាជិកអ្នកបកប្រែ

ព្រះភិក្ខុ ស៊ុន រិទ្ធី

ព្រះភិក្ខុ សុខ សុជាតា

លោក សុខ ៣

លោកស្រី សុខ ណារី

លោកស្រី ឡាទូ សៅរ៉ែន

លោកស្រីរួស ហ្វាន់នី

លោកស្រី អិន ណារិន

លោកស្រីវេជ្ជបណ្ឌិត អ៊ុកវង្ស វឌ្ឍនី

លោក សោម ចិត្រាវុឌ្ឍ